better factories Cambodia

# សេចក្ដីប្រកាសព័ត៌មាន

សម្រាប់ការផ្សាយបន្ទាន់

ថ្ងៃពុធ ទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩

## របាយការណ៍សំយោគទី ២៣ របស់គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ

## វិបត្តិសេដ្ឋកិច្ចអន្តរជាតិនៅតែមានផលប៉ះពាល់មកលើឧស្សាហកម្មកាត់ដេរ ប៉ុន្តែ ជាទូទៅល័ក្ខខ័ណ្ឌការងារនៅក្នុងរោងចក្រកាត់ដេរនៅតែល្អប្រសើរ

ភ្នំពេញ ប្រទេសកម្ពុជា– គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*នៃអង្គការពលកម្មអន្តរជាតិ (ILO) នៅថ្ងៃនេះ ចេញផ្សាយនូវ “របាយការណ៍សំយោគទី ២៣ ស្តីពីល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរកម្ពុជា” ដែលធ្វើការវាយតំលៃលើការអនុលោមទៅតាមច្បាប់ស្តីពីការងាររបស់ប្រទេសកម្ពុជា និងបទដ្ឋានការងារអន្តរជាតិនៅក្នុងរោងចក្រកាត់ដេរ។

របាយការណ៍សំយោគទី ២៣ នេះ គឺជារបាយការណ៍សំយោគទី៧ ដែលត្រូវចេញផ្សាយតាមរយៈការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានស្វ័យប្រវត្តិ (IMS) ដែលជាប្រព័ន្ធប្រើដើម្បីប្រមូល និងរក្សាទុកទិន្នន័យដែលទទួលបានពីការចុះត្រួតពិនិត្យមើលរោងចក្រ និងបង្កើតចេញជារបាយការណ៍។

របាយការណ៍សំយោគនេះមានផ្ទុកព័ត៌មានដ៏សំបូរបែប រួមមានការរកឃើញលើផ្នែកអនុលោមតាមសិទ្ធិជាមូលដ្ឋាន និងល័ក្ខខ័ណ្ឌការងារជាច្រើនផ្នែក ព្រមទាំងព័ត៌មានអំពីទំហំរោងចក្រនៅទូទាំងឧស្សាហកម្មនេះ។ ទិន្នន័យត្រូវបានបង្ហាញក្នុងរូបភាពជាតារាង និងក្រាហ្វិកដែលងាយស្រួលអាន។ របាយការណ៍សំយោគទី ២៣ នេះបានបន្ថែមនូវទិន្នន័យប្រៀបធៀបគ្នាទៅនឹងរបាយការណ៍សំយោគចំនួនពីរមុន ដើម្បីងាយស្រួលតាមដានកម្រិតនៃការអនុលោមតាមច្បាប់ក្នុងរយៈពេលកន្លងមក។

របាយការណ៍សំយោគនេះ បញ្ជាក់ថាកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងកាងារ និងក្រសួងពាណិជ្ជកម្ម សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងសហជីពដើម្បីធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់នូវល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរសំលៀកបំពាក់កម្ពុជា នៅតែបន្តមានលទ្ធផលជាវិជ្ជមានទៅលើបទដ្ឋានការងារ។

ទោះបីជាកង្វល់លើបញ្ហាមួយចំនួននៅតែមាន ជាពិសេសទាក់ទងនឹងសេរីភាពក្នុងការបង្កើតអង្គការវិជ្ជាជីវៈ និងការរើសអើងក្តី ក៏ជាទូទៅការអនុលោមតាមច្បាប់នៅតែមានកម្រិតខ្ពស់ ខណៈពេលដែលរោងចក្រប្រឈមនឹងសម្ពាធកាន់តែច្រើនជាងមុនដោយសារវិបត្តិសេដ្ឋកិច្ចក៏ដោយ (សូមមើលលទ្ធផលរកឃើញសំខាន់ៗខាងក្រោម)។

Better Factories Cambodia
International Labour Organization

#9, Street 322
Boeung Keng Kang I
Phnom Penh, Cambodia
PO Box 2642

Tel (+855) 23 212 847
(+855) 23 220 362
ext. 106/7
Fax (+855) 23 212 903
E-mail betterfactories@ilo.org
Website www.betterfactories.org/ilo

ទិន្នន័យរបស់ក្រសួងពាណិជ្ជកម្ម សម្រាប់រយៈពេលពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៨ ដល់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៩ បង្ហាញថា មានរោងចក្រចំនួន ៧០ បានបិទទ្វារ និង មានការបាត់បង់ការងារប្រមាណ ៧០០០០ ការងារ។ ឥលូវនេះ ច្រើនជាងពេលណាៗទាំងអស់ ដៃគូនានាក្នុងឧស្សាហកម្មនេះត្រូវផ្តោតសំខាន់លើការបង្កើនផលិតភាព និង រក្សាឱ្យបាននូវសន្តិភាពក្នុងឧស្សាហកម្ម ប្រយោជន៍ធានាបន្តភាពជោគជ័យរបស់ឧស្សាហកម្មនេះ និង ពង្រឹងឧស្សាហកម្មនេះ ក្រោយពេលវិបត្តិកើតមានឡើង។ គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា*កំពុងធ្វើការងារជាមួយនឹងនិយោជក និងសហជីព ដើម្បីព្យាយាមធានាឱ្យប្រាកដថា ក្នុងករណីដែលមានការបញ្ឈប់ការងាររបស់កម្មករនិយោជិត ការបញ្ឈប់នេះត្រូវធ្វើឡើងប្រកបដោយការទទួលខុសត្រូវ។

គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* និងទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិផ្សេងៗទៀត កំពុងធ្វើការជាមួយគ្នាដើម្បីស្វែងយល់ឱ្យបានកាន់តែច្បាស់ពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចនេះ មកលើកម្មករនិយោជិតម្នាក់ៗ និងបង្កើតគោលនយោបាយ និងវិធានការណ៍ ដើម្បីឆ្លើយតបយ៉ាងសមស្របដល់អ្នកទទួលផលប៉ះពាល់ដោយសារវិបត្តិនេះ។ ក្រោមកិច្ចសហការជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* កំពុងធ្វើការសិក្សាមួយដែលពិនិត្យមើលលើផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចរបស់វិបត្តិនេះមកលើក្រុមកម្មករនិយោជិតកាត់ដេរចំនួន ២០០០ នាក់ រាប់បញ្ចូលទាំងអ្នកមាន និងអ្នកគ្មានការងារធ្វើ។ លទ្ធផលជាបឋមនៃការសិក្សានេះបង្ហាញថា សូម្បីតែនៅក្នុងចំណោមកម្មករនិយោជិតដែលមានការងារធ្វើ ពួកគេចំនួនពាក់កណ្តាលទទួលបានចំណូលទាបជាងមុន បើប្រៀបធៀបនឹងឆ្នាំមុន។ ដោយសារតែកម្មករនិយោជិតភាគច្រើនជួយឧបត្ថម្ភដល់សមាជិកជាច្រើននាក់ក្នុងក្រុមគ្រួសារពីចំណូលដែលពួកគេរកបាន ការថយចុះចំណូលនេះមានផលប៉ះពាល់ជាច្រើន។ កម្មករនិយោជិតភាគច្រើនអាចសន្សំប្រាក់បានតិចតួច ដើម្បីជួយខ្លួនឯងឱ្យរួចផុតពីវិបត្តិនេះ ដូច្នេះមានភាពចាំបាច់ជាបន្ទាន់មួយ ដើម្បីបង្កើតនូវប្រព័ន្ធសុវត្ថិភាពសង្គមសម្រាប់ពេលបច្ចុប្បន្ន និងពេលអនាគត។

អង្គការពលកម្មអន្តរជាតិ ក៏កំពុងជួយដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបង្កើតមជ្ឈមណ្ឌលកាងារប្រចាំតំបន់ដើម្បីផ្តល់នូវការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជួយដល់កម្មករនិយោជិតដែលបាត់បង់ការងារ ដើម្បីស្វែងរកការងារថ្មី។ មជ្ឈមណ្ឌលការងារ ១ ត្រូវបានសម្ពោធបើកជាផ្លូវការកាលពីពេលថ្មីៗនេះនៅក្នុងទីក្រុងភ្នំពេញ ហើយមជ្ឈមណ្ឌលការងារចំនួន ៦ កន្លែងទៀតនឹងបើកឱ្យដំណើរការនៅត្រឹមចុងឆ្នាំ ២០១០។ មជ្ឈមណ្ឌលការងារទាំងនេះ នឹងផ្តល់សេវាជួយស្វែងរកឱកាសការងារ និងឱកាសបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់កម្មករនិយោជិតដែលគ្មានការងារធ្វើ និងគ្មានការងារធ្វើគ្រប់គ្រាន់នៅក្នុងគ្រប់វិស័យទាំងអស់។

កាលពីថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០៩ គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា*រួមជាមួយនឹងមជ្ឈមណ្ឌលឧស្សាហកម្មដើម្បីបង្កើនលទ្ធភាពផលិតសំលៀកបំពាក់ (GIPC) រាជរដ្ឋាភិបាលកម្ពុជា សមាគមនានាក្នុងឧស្សាហកម្មកាត់ដេរ និងទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិផ្សេងៗទៀត បានរួមគ្នាប្រារព្ធនូវយុទ្ធនាការឈ្មោះថា «ខ្ញុំមានតំលៃ» ជាលើកទីពីរ ដែលជាយុទ្ធនាការធ្វើឡើងដើម្បីលើកតំលៃកម្មករនិយោជិតកាត់ដេរនៅកម្ពុជាដោយសង្កត់ធ្ងន់លើតំលៃនៃការងារដែលគេធ្វើ និង ដើម្បីឱ្យពួកគេមានឱកាសបង្ហាញពីទេពកោសល្យរបស់ខ្លួនតាមរយៈការប្រកួតប្រជែងរចនាម៉ូតសំលៀកបំពាក់និងអាវយឺត។ ព្រឹត្តិការណ៍នេះគឺជាជោគជ័យដ៏ធំធេងមួយ ហើយរង្វាន់សម្រាប់ជ័យលាភីរួមមាន ការបណ្តុះបណ្តាលធ្វើពុម្ពគំរូដើម្បីផ្តល់លទ្ធភាពឱ្យអ្នកឈ្នះការប្រកួតសម្រេច

បំណងប្រាថ្នានិងបង្កើនជំនាញរបស់ខ្លួន។ ជាពិសេសនៅក្នុងកាលៈទេសៈដែលប្រឈមនឹងវិបត្តិសេដ្ឋកិច្ចបែបនេះ វាជារឿងសំខាន់ណាស់ក្នុងការលើកកំពស់រូបភាពជាវិជ្ជមានរបស់ឧស្សាហកម្មកាត់ដេរ។

របាយការណ៍សំយោគទី ២៣ នេះបង្ហាញនូវតួលេខអនុលោមតាមច្បាប់ដែលផ្អែកទៅលើទិន្នន័យពិនិត្យឃ្លាំមើល ដែលមាននៅក្នុងរបាយការណ៍រោងចក្រចំនួន ១៧២ ដែលត្រូវបានបំពេញនៅរវាងថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០០៩ និងថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៩ នេះ។

លទ្ធផលដែលបានរកឃើញសំខាន់ៗមួយចំនួន មានដូចតទៅ ÷

- វិបត្តិហិរញ្ញវត្ថុពិភពលោកមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើឧស្សាហកម្មកាត់ដេរនៅកម្ពុជា។ វិបត្តិនេះនាំឱ្យមានការបញ្ឈប់ការងារកម្មករនិយោជិត ហើយរោងចក្រជាច្រើនត្រូវបិទទ្វារ។ ផលប៉ះពាល់ទាំងនេះត្រូវបានបន្ធូរបន្ថយបានខ្លះដោយសារមានការបើករោងចក្រថ្មីៗមួយចំនួន។ផ្អែកតាមទិន្នន័យដែលទទួលបានពីការចុះឃ្លាំមើលល័ក្ខខ័ណ្ឌការងារ ចំនួនកម្មករនិយោជិតដែលមានការងារធ្វើសព្វថ្ងៃនេះបានថយចុះចំនួនប្រមាណ ៤៨០០០ នាក់ រវាងពីថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០០៨ ដល់ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០០៩។
- ៨៤% នៃរោងចក្រដែលបានត្រួតពិនិត្យមើល មានកម្មករនិយោជិតតិចជាង ២០០០ នាក់ ។
- ៧៦% នៃរោងចក្រដែលបានត្រួតពិនិត្យមើល មានសហជីពយ៉ាងហោចណាស់មួយ ពោលគឺថយចុះចំនួន ៧% ពីរបាយការណ៍សំយោគទី ២២។
- មានភាពប្រសើរឡើងតិចតួចលើកម្រិតអនុលោមតាមច្បាប់ ចំពោះល័ក្ខខ័ណ្ឌដែលពាក់ព័ន្ធនឹងសិទ្ធិជាមូលដ្ឋាន បើប្រៀបធៀបជាមួយនឹងរបាយការណ៍មុន។ ភាគរយនៃរោងចក្រ ដែលរើសអើងចំពោះកម្មករនិយោជិត (ជាធម្មតា ការរើសអើងលើភេទ) មានចំនួន ១០% ពោលគឺថយចុះពី ១៣% នៅក្នុងរបាយការណ៍មុន។ ភាគរយនៃការរើសអើងប្រឆាំងនឹងសហជីពគឺ ១% ថយចុះពីកម្រិត ២% នៅក្នុងរបាយការណ៍មុន។ ហើយ ភាគរយនៃរោងចក្រដែលរារាំងដល់សិទ្ធិសេរីភាពបង្កើតអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិតមានចំនួន ៣% គឺថយចុះពី ៥% នៅក្នុងរបាយការណ៍មុន។
- មានកម្មករនិយោជិតក្រោមអាយុចំនួន ១ នាក់ត្រូវបានរកឃើញ។
- រោងចក្រដែលបានត្រួតពិនិត្យមើលចំនួន ១៤% មានកូដកម្ម (គ្មានការផ្លាស់ប្តូរពីរបាយការណ៍មុន)។
- ការអនុលោមទៅតាមល័ក្ខខ័ណ្ឌប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតពេញសិទ្ធិ គឺមានកម្រិត ១០០% ពោលគឺកើនឡើងពីកម្រិត ៩៩% នៅក្នុងរបាយការណ៍មុន។ សម្រាប់កម្មករនិយោជិតម្តងម្កាលវិញ ការអនុលោមទៅតាមច្បាប់ក្នុងការផ្តល់ប្រាក់ឈ្នួលអប្បបរមា គឺនៅថេរត្រឹម ៨៩% ក្នុងរោងចក្រដែលជួលកម្មករនិយោជិតម្តងម្កាល។
- ការអនុលោមទៅតាមច្បាប់ស្តីពីការឈប់សម្រាកប្រចាំឆ្នាំ ការឈប់សម្រាកឈឺ និងការឈប់សម្រាកលំហែរមាតុភាព មិនមានការផ្លាស់ប្តូរលើសពី ២% ឡើយ បើប្រៀបធៀបជាមួយនឹងរបាយការណ៍មុន។
- ការអនុលោមទៅតាមច្បាប់ស្តីពីកំហិតភាពញឹកញាប់ និងរយៈពេលនៃការធ្វើការបន្ថែមម៉ោង មានការកើនឡើងចំនួន ៥% និង ៣% ហើយចំនួនរោងចក្រធ្វើការបន្ថែមម៉ោងដោយស្ម័គ្រចិត្តកើនឡើងចំនួន ៥%។ កំណើនទាំងនេះគឺមានបន្តពីរបាយការណ៍មុន ហើយអាចដោយសារតែមានការថយចុះបរិមាណបញ្ជាទិញដែលធ្វើឱ្យការងារបន្ថែមម៉ោងក៏ថយចុះផងដែរ។

- ការអនុលោមទៅតាមល័ក្ខខ័ណ្ឌផ្តល់ឧបករណ៍ការពារផ្ទាល់ខ្លួន និង ការតម្លើងរបាំងការពារម្ជុលលើម៉ាស៊ីនដេរ មានការកើនឡើងចំនួន ២%។
- បញ្ហា ៦ ក្នុងចំណោមបញ្ហាទាំង ១០ ស្តីពីការមិនអនុលោមតាមច្បាប់ក្នុងរបាយការណ៍សំយោគលើកទី ២៣ នេះ ក៏មានដូចនៅក្នុងរបាយការណ៍មុនដែរ។ ជាទូទៅ កម្រិតនៃការមិនអនុលោមតាមច្បាប់ពេលនេះមានកម្រិតទាបជាងក្នុងរបាយការណ៍មុន ដែលនេះជាសញ្ញាបង្ហាញពីភាពប្រសើរជារួម។

«របាយការណ៍សំយោគទី ២៣ ស្តីពីល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរនៅកម្ពុជា» មានជាភាសា**ខ្មែរ អង់គ្លេស** និង**ចិន** ដែលអាចរកបាននៅលើវ៉ិបសាយ www.betterfactories.org ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
លោក វុធ លីណូ
មន្ត្រីទំនាក់ទំនងព័ត៌មាន
អ៊ីម៉េល៖ g6bfc@ilo.org
ទូរស័ព្ទ៖ 012 756 765